ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះយេស៊ូជ្រើសរើសអ្នកជំនួយដប់ពីរនាក់



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus
Alastair Paterson

កែសម្រួលដោយ៖ E. Frischbutter; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

ព្រះយេស៊ូបានធ្វើការអស្ចារ្យជាច្រើន។ ព្រះអង្គបានប្រោសអ្នកជម្ងឺឲ្យបានជា, ប្រទានឲ្យមនុស្សដែលមានបញ្ហាបានស្ងប់ចិត្តគំនិត ព្រមទាំងបានបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ផង។



មានមនុស្សជាច្រើន បានចូលមករកព្រះយេស៊ូដើម្បីទទួលជំនួយ និង
ការប្រោសឲ្យជាពីព្រះអង្គ។ ព្រះអង្គបានសព្វព្រះហឫទ័យ ជ្រើសរើស
មនុស្សប្រុសចំនួនដប់ពីរនាក់ពីក្នុងចំណោមអ្នកដំណើតាមជាច្រើន
ដើម្បីជួយព្រះអង្គបំពេញកិច្ចការរបស់ព្រះ
ជាម្ចាស់។



ប្រសិនបើ យើងមានជម្រើសដ៏សំខាន់បំផុត, តើយើងនឹងអធិស្ឋានទូលសុំព្រះជាម្ចាស់ឬទេ? ព្រះយេស៊ូ បានធ្វើការនោះ។ ព្រះអង្គបានទូលទៅកាន់ព្រះបិតាដែលគង់នៅឋានសួគ៌ ពីកន្លែងដ៏ស្ងប់ស្ងាត់មួយនៅលើភ្នំ។ ព្រះយេស៊ូបានអធិស្ឋាន រហូតដល់ថ្ងៃរះឡើង។




ព្រះយេស៊ូបានអធិស្ឋានពេញមួយយប់។

លុះព្រឹកឡើង ព្រះយេស៊ូបានត្រាស់ហៅអ្នកដើរតាមព្រះអង្គ,
គឺមិត្តសម្លាញ់ដែលបម្រើ និង ស្តាប់បង្គាប់ព្រះអង្គ។ ព្រះអង្គបាន
ជ្រើសអ្នកជំនួយដ៏ពិសេស ឬសាវ័កចំនួនដប់ពីរនាក់
ពីក្នុងចំណោមអ្នកទាំងនោះ។



ព្រះយេស៊ូបានជ្រើសរើសបងប្អូនពីរនាក់ គឺលោកស៊ីម៉ូន-ពេត្រុស
និង លោកអនទ្រេជាប្អូន។ អ្នកទាំងពីរក៏លះបង់មុខរបជាអ្នក
នេសាទ រួចដើរតាមព្រះអង្គទៅ។



លោកយ៉ាកុប និង លោកយ៉ូហាន
ជាកូនរបស់លោកសេបេដេ
ក៏បានចាកចោលទូក ចាកចោលឪពុក
និងចាកចោលអ្នួន ហើយដើរតាមព្រះយេស៊ូផងដែរ។



ព្រះយេស៊ូ ក៏បានជ្រើសរើស លោកភីលីព, លោកបាថូឡូម៉េ,
លោកម៉ាថាយ, លោកថូម៉ាស, លោកស៊ីម៉ូន ជាអ្នកជាតិនិយម,
លោកយ៉ាកុប ជាកូនរបស់លោកអាល់ផាយ,
លោកយ៉ូដាស ជាប្អូនរបស់លោកយ៉ាកុប,
និង លោកយ៉ូដា-អ៊ីស្ការីយ៉ុត
ជាអ្នកក្បត់ព្រះអង្គ។



ព្រះយេស៊ូបានបង្រៀនថា ការធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ
ប្រៀបដូចជាបុរសម្នាក់ដែលសង់ផ្ទះនៅលើគ្រឹះដ៏រឹងមាំ។
ព្យុះកំណាចនានា
មិនអាចបំផ្លាញផ្ទះនោះ
បានសោះឡើយ។



ប៉ុន្តែ អស់អ្នកដែលមិនធ្វើតាមព្រះបន្ទូលរបស់ព្រះយេស៊ូវិញ ប្រៀបដូចជាបុរសម្នាក់ទៀត ដែលសង់ផ្ទះរបស់ខ្លួននៅលើគ្រឹះមិនរឹងមាំ។ ព្យុះកំណាច ក៏បក់បោកបំផ្លាញផ្ទះនោះខ្ទេចខ្ទីអស់រលីង។



សេចក្ដីបង្គាប់របស់ព្រះយេស៊ូមួយចំនួនមិនងាយស្រួលធ្វើតាមនោះ
ទេ។ ព្រះអង្គមានបានបង្រៀនថា ៖” ប្រសិនបើគេទះកំផ្លៀងអ្នកម្ខាង
ចូរបែរឲ្យគេទះម្ខាងទៀតចុះ។
ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក”។
មនុស្សលោកត្រូវការជំនួយរបស់ព្រះជាម្ចាស់
ក្នុងការរស់នៅដូចអង្គព្រះយេស៊ូ។



ព្រះយេស៊ូក៏បានបង្រៀនឲ្យអធិស្ឋាននៅក្នុងស្ងាត់កំបាំង
ដោយមិនត្រូវធ្វើនៅចំពោះមុខមនុស្សលោក ដូចអ្នកដឹកនាំសាសនា
មួយចំនួននោះឡើយ។



ព្រះយេស៊ូមានព្រះបន្ទូលថា
ព្រះជាម្ចាស់នឹងប្រទានសម្លៀកបំពាក់
និង ម្ហូបអាហារដល់អស់អ្នកដែល
ទុកចិត្តព្រះអង្គ។ ព្រះជា ម្ចាស់បានប្រទាន
អាហារដល់បក្សាបក្សី និង ផ្តល់ឲ្យផ្កាមាន
សម្រស់ដ៏ស្រស់ស្អាតយ៉ាងនេះទៅហើយ
ចុះចំណង់បើអស់អ្នកដែលទុកចិត្តលើព្រះអង្គ
ទ្រង់ក៏នឹងបំពេញគ្រប់ទាំងសេចក្តីត្រូវរបស់គេផង។



ព្រះយេស៊ូបានបង្រៀនអ្នកដែលព្រះអង្គបានជ្រើសរើសឲ្យធ្វើកិច្ចការជាច្រើននៅគ្រានោះ។ កាលទ្រង់បានបង្រៀនគេចប់សព្វ គ្រប់ហើយ ក៏មានមនុស្សឃ្លង់ម្នាក់ចូលមករក ហើយទូលសុំឲ្យព្រះយេស៊ូប្រោស គាត់ឲ្យបានជាស្អាត។



ព្រះយេស៊ូ បានឆ្លើយតបទៅវិញថា ៖ “ខ្ញុំចង់ដែរ សូមឲ្យបានជាស្អាត ចុះ”។ មនុស្សឃ្លង់នោះ ក៏បានជាស្អាតនៅចំពោះមុខអ្នកដែលព្រះអង្គ ជ្រើសរើសទាំងដប់ពីនាក់។ មនុស្សនោះ បានជាស្អាត។ មានតែព្រះបុត្រា របស់ព្រះជាម្ចាស់ប៉ុណ្ណោះ អាចធ្វើកិច្ចការនោះបាន។ អ្នកជំនួយទាំងដប់ពីរនាក់បាន ដឹងថា ពួកគេមានគ្រូដ៏អ ស្ចារ្យមួយអង្គ។



ព្រះយេស៊ូជ្រើសរើសអ្នកជំនួយដប់ពីរនាក់

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ៤-៧, ម៉ាកុស ១, លូកា ៦

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម៉្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យូហាន ៣៖១៦